ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៦៧/២១ អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តពោធិ៍សាត់»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ម៉ក់ រ៉ា ប្រធានក្រុមប្រឹក្សាខេត្តពោធិ៍សាត់**
- **ឯកឧត្តម អ៊ុំ គឹមលាង អភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់**
- **លោកស្រី ចាន់ សុជាតិ ចៅសង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តពោធិ៍សាត់ មានផ្ទៃដីសរុបចំនួន ១២.៦៩២ គ.ម២ ស្មើនឹង១.២៦៩.២០០ហ.ត និងចែកចេញជា ០១ រដ្ឋបាលក្រុង ០៦ រដ្ឋបាលស្រុក ០៧ សង្កាត់ ៤២ឃុំ និង៥១១ភូមិ ដែលមានប្រជាជនសរុបចំនួន ៥០០,៦៩៩ នាក់ ស្រី ២៤៧,៥៨៧ នាក់ ស្មើនឹង ១១៩,៧០៩ គ្រួសារ មេគ្រួសារជាស្ត្រីចំនួន ១៧.៦៧%។ មានមុខរបរជាកសិករ ៧៥.៨% សេវាករ ២៣.៥% និងសិប្បករ ០.៧%។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- ការងារកសិកម្ម៖ បានអនុវត្តដាំដុះបានចំនួន ១៤៥.៣៤២ ហិកតា ប្រៀបធៀបឆ្នាំ២០១៩ ខ្ពស់ជាងឆ្នាំមុន ក្នុងនោះ៖ ស្រូវស្រាល ៧០.៧៥០ ហិកតា ស្រូវកណ្ដាល ៥៣.៤៧០ ហិកតា ស្រូវធ្ងន់ ១៥.៤៧៨ ហិកតា ស្រូវចម្ការ ៨៨៣ ហិកតា ស្រូវឡើងទឹក ១.៧៦០ ហិកតា និងស្រូវបង្កើនរដូវ ៣.០០១ ហិកតា។ មានដំណាំរួមផ្សំដូចជាបន្លែគ្រប់មុខ ឪឡឹក ម្ទេស ល្ពៅ ម្នាស់ និងដំឡូងផ្លា និងដំណាំកសិឧស្សាហកម្មលក្ខណៈគ្រួសារ រួមមាន៖ ដំឡូងមី ពោតក្រហម ពោតស អំពៅ ដំណាំល្ង សណ្ដែកដី សណ្ដែកបាយ សណ្ដែកអង្គុយ សណ្ដែកសៀង ត្រាវ សាគូ ខ្ញី និងរមៀត។
- វិស័យធនធានទឹក៖ មានប្រព័ន្ធធារាសាស្ត្រធំៗ មាន០៣កន្លែងរួមមាន៖ ប្រព័ន្ធធារាសាស្ត្រចារឹក ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីសរុប ៤៥.០០០ ហិកតា និងមានប្រព័ន្ធធារាសាស្ត្រមធ្យម និងតូចសរុប ២៧កន្លែង សំណង់បង្ហៀរមានចំនួន ០៥កន្លែង ប្រឡាយមេ និងប្រឡាយរងសរុបចំនួន ១២៦ខ្សែ និងទំនប់ទី៣ ទី៥ ដែលអាចផ្ទុកទឹកសរុប ៥០ លានម៉ែត្រគូប។
- វិស័យឧស្សាហកម្ម៖ មានរោងចក្រចំនួន ៥ មូលដ្ឋាន ក្នុងនោះ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មមានចំនួន ២៤២មូលដ្ឋាន ស្ពាននីយ៍ និងដេប៉ូចំនួន ១២០ មូលដ្ឋាន។
- វិស័យទេសចរណ៍៖ មានកន្លែងទេសចរណ៍ធម្មជាតិ សាសនា និងវប្បធម៌ចំនួន ៣៥ កន្លែង ដោយក្នុងឆ្នាំ២០២០ មានស្ថិតិភ្ញៀវទេសចរសរុបចំនួន ៤៤០.៩២៩នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិមានចំនួន ៤៣៨.៥៥៣នាក់ និងភ្ញៀវទេសចរអន្តរជាតិមានចំនួន ២.៣៧៦ នាក់។
- ការងារវិនិយោគ៖ មានក្រុមហ៊ុនវិនិយោគឯកជនសរុបចំនួន ១៨ ក្រុមហ៊ុន បាន និងកំពុងសហការបង្កើតរោងចក្រ ដែលបានបោះទុនវិនិយោគសរុបប្រមាណជាង ១.០០០ លានដុល្លារ។

- វិស័យសុខាភិបាលៈ មានការិយាល័យស្រុកប្រតិបត្តិចំនួន ០៤ មន្ទីរពេទ្យបង្អែកចំនួន ០៤ មណ្ឌលសុខភាពចំនួន ៤០ និងប៉ុស្តិ៍សុខភាពចំនួន០២ ដោយមានគម្រោងមូលនិធិសមធម៌ និងបេឡាជាតិ របបសន្តិសុខសង្គម គ្រប់ដណ្តប់គ្រប់មន្ទីរពេទ្យ និងមណ្ឌលសុខភាពទាំងអស់ក្នុងខេត្ត។
- បានប្រជុំទៀងទាត់ស្របតាមប្រតិទិនស្តីពីកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត។
- បានរៀបចំធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត ដោយមានឆ្លើយតបនឹងសំណួរ និងសំណូមពរ ដែលប្រជាពលរដ្ឋបានលើកឡើងមានចំនួន ១៣២សំណួរ និងសំណូមពរ ដោយបានដោះស្រាយផ្ទាល់បាន ៩៥% នៅសល់ ៥%ទៀត នឹងដោះស្រាយបន្តនៅពេលក្រោយ។
- បានរៀបចំកិច្ចប្រជុំសម្ងាត់ដើម្បីវាយតម្លៃតែងតាំង ផ្លាស់ប្តូរមុខតំណែងមន្ត្រី ស្របតាមលិខិតបទដ្ឋាន គតិយុត្ត និងប្រកបដោយយុត្តិធម៌។
- បានរៀបចំសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច ជូនដល់សមាជិកក្រុមប្រឹក្សាខេត្ត ជួបប្រាស្រ័យទាក់ទង និងសហការជាមួយក្រុមប្រឹក្សាក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ទីរអង្គភាពជំនាញ និងជាមួយប្រជាពលរដ្ឋក្នុងខេត្ត។

❖ **សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់**

- ការងារអប់រំៈ មានវិទ្យាល័យ ២កន្លែង, អនុវិទ្យាល័យចំនួន ១កន្លែង, សាលាបឋមសិក្សារដ្ឋ ៣កន្លែង, មត្តេយសិក្សា ២កន្លែង, មត្តេយ្យសហគមន៍០១។
- ការងារហេដ្ឋារចនាសម្ព័ន្ធៈ មានផ្លូវក្រាលគ្រោះក្រហមប្រវែង ២៤.៣៣៦ម៉ែត្រក្លាយទៅជាបេតុង៩ខ្សែចំនួន២.០៨៩ម៉ែត្រ។
- ការងារសង្គមកិច្ចៈ បានផ្តល់ប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋក្រីក្រចំនួន ៥០៣គ្រួសារ ក្រ១. ៨២ គ្រួសារ ក្រ២. ៤២១គ្រួសារ, ផ្តល់ប័ណ្ណសមធម៌ជូនដល់ ប្រជាពលរដ្ឋក្នុងអំឡុងពេលកូវីត១៩ ចំនួន២០៩គ្រួសារ ក្រ១. ៨៨គ្រួសារក្រ២.១២១គ្រួសារ និងនាមផ្តល់កាតវីងក្នុងកម្មវិធីឧបត្ថមសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារក្រោមអាយុ២ឆ្នាំចំនួន៦១ប័ណ្ណ។
- ការងារសណ្តាប់ធ្នាប់សាធារណៈៈ ដោយអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ការងារការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងឃុំទាំងមូលជារួម គឺរក្សានូវសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ សាធារណៈជូនប្រជាពលរដ្ឋ។

- ការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩៖ ដោយបានអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងវិធានការរបស់ក្រសួងសុខាភិបាល យន្តការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ-១៩ ឃុំបាន រៀបចំកន្លែងដាក់ចត្តាឡីស័កឃុំ ដើម្បីគ្រប់គ្រងលើផ្នែកសុខភាព និងការដាក់ឱ្យនៅដាច់ដោយ ឡែករយៈពេល១៤ថ្ងៃ ចំពោះប្រជាពលរដ្ឋមកពីក្រៅប្រទេស។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

- ចូលរួមពិនិត្យ និងដោះស្រាយសំណើ សំណូមពរ បញ្ហាប្រឈម និងកង្វល់នានាដែលប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានបានស្នើឡើងស្របតាមច្បាប់ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត។
- ជំរុញការតាមដាន វាយតម្លៃការអនុវត្តសេចក្ដីសម្រេច របស់ក្រុមប្រឹក្សាដែលបានដាក់ចេញក្នុងពេលកន្លងមក ពិសេសការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានសម្រេចដាក់ចេញសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងខេត្ត ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ គោលដៅ និងគោលបំណងនៃការអភិវឌ្ឍក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត។
- បន្តប្រាស្រ័យទំនាក់ទំនងជាមួយយន្តការរបស់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ ដើម្បីមានមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ បានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅជាធរមាន។
- អនុវត្តកម្មវិធីប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ដែលបានកំណត់ក្នុងប្រតិទិនប្រជុំ និងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត។
- បន្តរៀបចំផែនការសម្រាប់ធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សានៅតាមមូលដ្ឋានក្រុង ស្រុកទាំង៧ ក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ។
- បង្កើនការអប់រំផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានា ដើម្បីរៀបចំព្រមទាំង អនុវត្តផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលឈានទៅកាត់បន្ថយ នូវផលប៉ះពាល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។
- បន្តគាំទ្រ និងជំរុញ ការទប់ស្កាត់ការរីករាលដាលជំងឺCOVID-19 និងបន្តចូលរួមក្នុងការផ្សព្វផ្សាយនូវវិធានការ របស់រាជរដ្ឋាភិបាល និងរបស់ក្រសួងសុខាភិបាល។

- ❖ **សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់**

- បន្តការយកចិត្តទុកដាក់បំរើសេវារដ្ឋបាលជូនប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័សប្រកបដោយបរិយាប័ន្ន។
- បន្តខិតខំបង្រឹងកំលាំងនគរបាលប៉ុស្តិ៍ និងប្រជាការពារ ដើម្បីអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មាន សុវត្ថិភាព អោយបានល្អ។
- ផ្សព្វផ្សាយ និង ផ្តល់ឪកាស អោយប្រជាពលរដ្ឋ យល់ដឹង អំពីច្បាប់ និង លិខិតបទដ្ឋាននានា គោលការណែនាំ បញ្ជ្រាបចំណេះដឹង ជូនដល់ប្រជាពលរដ្ឋ។
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំ រំកិល និង អនុវត្តគម្រោងមូលនិធិសង្កាត់អោយបានទាន់ពេលវេលា។
- បន្តផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ជំងឺ ឆ្លងនានា ជាពិសេស ជម្ងឺកូវីដ១៩ តាមការណែនាំរបស់
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋអោយចេះវេចខ្ចប់ទុកដាក់ សំរាម និង កាកសំណល់ឱ្យត្រឹមត្រូវ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១